# ព្រះវិហារចាស់មួយនៅក្នុងវត្តទ្រាំង

វត្តទ្រាំង (ឬតាឡវនារាម) ជាអារាមចំណាស់មួយស្ថិតនៅបណ្ដោយដងទន្លេមេគង្គ ជាប់នឹងផ្លូវលេខ៣៨១ ក្នុងភូមិទ្រាំងក្រោម ឃុំតាឯក ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល។ បច្ចុប្បន្ននៅក្នុងវត្តនេះ មានសមិទ្ធផលជាច្រើនកសាងឡើងជាបន្តបន្ទាប់តាំងពីកកើតវត្តរហូតមក ដែលមានព្រះវិហារពីរសាងទន្ទឹមគ្នា ស្ថិតនៅស្ទើរចំកណ្ដាលផ្ទៃដីវត្ត។ ផ្នែកខាងជើងមានសាលាឆាន់និងរោងទូក ផ្នែកខាងត្បូងមានកុដិតូចធំជាច្រើនខ្នងនិងសាលាបាលី ផ្នែកខាងលិចមានរោងបាយ និងខាងកើតព្រះវិហារមានចេតិយ ស្រះទឹកតូចមួយ ព្រមទាំងមានខ្លោងទ្វារនិងច្រកចូលគ្រប់ទាំងបួនទិស(រូបលេខ១)។



*រូបលេខ១ គំនូរបង្ហាញពីទិដ្ឋភាពទូទៅនៃបរិវេណវត្តទ្រាំង*

ដូចបានលើកឡើងខាងលើ ក្នុងបរិវេណវត្តទ្រាំងសព្វថ្ងៃមានព្រះវិហារពីរ កសាងឡើងនៅលើខឿនតែមួយ(រូបលេខ២)។ ព្រះវិហារខាងជើងជាព្រះវិហារបុរាណ ចំណែកឯព្រះវិហារខាងត្បូងជាព្រះវិហារសង់ថ្មី។ ប៉ុន្តែនៅក្នុងអត្ថបទខ្លីនេះខ្ញុំសូមរៀបរាប់ត្រួសៗតែព្រះវិហារខាងជើង ជាព្រះវិហារតូចមួយដែលគេមើលឃើញជាសំណង់បុរាណ ហើយ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

*កសាងឡើងប្រកបទឹកដៃសិល្បៈស្ថាបត្យកម្ម តុបតែងក្បាច់លម្អរួមបញ្ចូលរវាងក្បាច់ឆ្លាក់ពីឈើ ក្បាច់ទឹបមាស និងគំនូរលើហប់ខ្យល់(រូបលេខ២)។*



*រូបលេខ២ ព្រះវិហារបុរាណ និងព្រះវិហារថ្មីសព្វថ្ងៃនៅវត្តទ្រាំង (រូបមើលពីជ្រុងឦសាន)*

*ព្រះវិហារបុរាណវត្តទ្រាំង បានកសាងឡើងនៅលើខឿន២ថ្នាក់ មានទំហំតូចល្មម ហើយសមក្អែកសមខ្នាតគ្រប់ជ្រុង។ ខឿនថ្នាក់ទី១ ព័ទ្ធជុំវិញព្រះវិហារបង្កើតបានជាទីធ្លាទូលាយសម្រាប់ដើរដង្ហែប្រទក្សិណពេលធ្វើកិច្ចពិធី ឬបុណ្យទានផ្សេងៗ ហើយក៏ជាខឿនដែលបានជួសជុសបន្ថែមកន្ទងមកដែរ។ ចំណែកខឿនថ្នាក់ទី២ មានកម្ពស់ប្រហែលត្រឹមចង្កេះ គឺជាផ្នែកមួយនៃគ្រឹះព្រះវិហារ ដែលទ្រទ្រង់រចនាសម្ព័ន្ធសំណង់ឱ្យមើលឃើញលេចត្រដែតឡើង។ ដោយឡែកតួព្រះវិហារសង់ឡើងអំពីឥដ្ឋ ជញ្ជាំងបិទជិតជុំវិញ ពោលគឺពុំមានចន្លោះបាំងសាច ដោយទុកឲ្យមានតែទ្វារចេញចូលខាងមុខចំនួន២ និងខាងក្រោយចំនួន២។ ជញ្ជាំងសងខាងពុំមានទ្វារដូចបណ្ដាព្រះវិហារផ្សេងៗឡើយ តែមានបង្អួចតូចៗមួយចំនួនជួយឲ្យពន្លឺភ្លឺស្រឡះល្អ និងខ្យល់អាចចេញចូលបានងាយ។ មិនតែប៉ុណ្ណោះនៅ*

*អត្ថបទដោយ៖ ហៀន សុវណ្ណមរកត*

ជញ្ជាំងខាងមុខមានរចនាសិល្បៈក្បាំងមុខលម្អផង ហើយស៊ុមបង្អួចនិងស៊ុមទ្វារ ទំនងជាបានជួសជុលកែថែមថយក្បាច់ក្ងីអង្គរដែលជាស្នាដៃសិល្បៈចម្លាក់ថ្មី(រូបលេខ៣-៤)។



រូបលេខ៣-៤ រចនាសម្ព័ន្ធជញ្ជាំងជុំវិញព្រះវិហារលម្អដោយក្បាច់ភ្ញីអង្គរលើស៊ុមទ្វារ និងស៊ុមបង្អួច

ព្រះវិហារវត្តទ្រាំងអាចចាត់ជាព្រះវិហារជហ្វា៤ ឬគេហៅជាទូទៅថា "ព្រះវិហារបុរាណ"[1] មានស្ទាបដំបូល១ជាន់ ប្រក់ក្បឿងស្រកាលេញ ហើយមានហប់ខាងមុខនិងក្រោយ លម្អដោយជហ្វា២នៅចុងដំបូលខាងមុខ ជហ្វា២នៅចុងដំបូលខាងក្រោយ និងក្បាលនាគនៅតាមចុងចែងដំបូល។ បន្ថែមពីលើនេះ ពាក់ព័ន្ធនឹងសំណង់ព្រះវិហារបុរាណខាងលើ ចំណុចគួរឲ្យចាប់អារម្មណ៍ គឺហោជាងនិងក្បាច់លម្អលើហោជាង ដែលគេមើលឃើញថា ក្បាច់ភ្ញីទេសឆ្លាក់ពីឈើ និងកញ្ចក់សំណាពណ៌បៃតងល្បាយខៀវចាស់លម្អជាផ្ទៃនៃហោជាងទាំងពីរ (រូបលេខ៥-៦)។



រូបលេខ៥-៦ ក្បាច់ភ្ញីទេសឆ្លាក់ពីឈើ និងល្បាយសំណាលម្អផ្ទៃហោជាងទាំងសងខាងនៃព្រះវិហារវត្តទ្រាំង

[1] ព្រាប ចាន់ម៉ារ៉ា, ២០១៧: ១៣-២៣

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# *អត្ថបទ៖ ព្រះវិហារចាស់មួយនៅក្នុងវត្តទ្រាំង*

*បើយកការសិក្សាស្រាវជ្រាវរបស់ Danielle & Dominique-Pierre Guéret ជាគោលគេយល់ថា ព្រះវិហារបុរាណវត្តទ្រាំងកសាងឡើងតាំងពីឆ្នាំ១៩២០ ហើយគំនូរខាងក្នុងព្រះវិហារសាងឡើងក្នុងឆ្នាំ១៩៤០។[2] ដូច្នេះក្នុងន័យនេះបានសេចក្តីថា ការកសាងព្រះវិហារ និងការសាងគំនូរខាងក្នុងព្រះវិហារ ធ្វើឡើងមុនក្រោយគ្នារយៈពេល២០ឆ្នាំ។ មិនតែប៉ុណ្ណោះគំនូរដែលលើកឡើងថាសាងក្នុងឆ្នាំ១៩៤០ ប្រហែលជាគំនូរឃើញនៅលើពិតានត្រង់ល្វែងគ្រឹះ និងគំនូរលើហប់ខ្យល់សព្វថ្ងៃ។ ប៉ុន្តែគំនូរដទៃផ្សេងទៀតគូរនៅលើជញ្ជាំង ឬគូរនៅលើពិតានដែលឃើញបច្ចុប្បន្ន ជាគំនូរថ្មីសាងក្រោយការជួសជុលព្រះវិហារកាលកន្លងមក។*

*ផ្នែកខាងក្នុងព្រះវិហា គេឃើញមានសសរឈើពីរជួរអមល្វែងគ្រឹះ និងរបៀងសងខាងស្ថិតនៅជាប់ជញ្ជាំង បង្កើតបានលំហតូចល្មមសមរម្យសម្រាប់ការរៀបចំពិធីបុណ្យទានផ្សេងៗ។ នៅតាមសសរនីមួយៗសុទ្ធតែលម្អដោយរូបនាគព័ន្ធព័ទ្ធរុំសសរពីលើចុះមកក្រោម។ បច្ចុប្បន្ននៅផ្នែកខាងក្នុងព្រះវិហារនេះដែរ គំនូរលើជញ្ជាំងជុំវិញជាគំនូរថ្មីរៀបរាប់រឿងពុទ្ធប្រវត្តិ និងរឿងជាតកនានាដូចបណ្តាព្រះវិហារដទៃ។ មិនតែប៉ុណ្ណោះចំពោះគំនូរពិតានខាងលើរបៀងទាំងសងខាង ក៏ប្រហែលជាគំនូរថ្មីសាងឡើងក្រោយជួសជុលព្រះវិហារ ដូចបានបញ្ជាក់មកខ្លះពីខាងដើម។ រីឯព្រះដីវធំក្នុងព្រះវិហារ ក៏បានជួសជុល និងសាងឡើងជាថ្មីក្នុងឆ្នាំ១៩៨១ដែរ ពោលគឺជាព្រះបដិមាថ្មីសាងក្រោយសម័យសង្គ្រាម (រូបលេខ៧-៨)។*



*រូបលេខ៧-៨ ទិដ្ឋភាពបច្ចុប្បន្ននៃផ្នែកខាងក្នុងព្រះវិហារវត្តទ្រាំង*

[2] Danielle & Dominique-Pierre Guéret; 2017, 107

*អត្ថបទដោយ៖ ហៀន សុវណ្ណមរកត*

ដោយឡែកចំពោះសិល្បៈលម្អលើធ្នឹមឈើខាងក្នុងព្រះវិហារ គឺជាក្បាច់ទឹបមាស ដែលប្រហែលជាក្បាច់បុរាណនៅសេសសល់តាំងពីដើមមក។ សិល្បៈទឹបមាសបែបនេះ គេឃើញមានសេសសល់មិនច្រើនឡើយលើសំណង់មកដល់បច្ចុប្បន្ន ហើយជាសិល្បៈដែលនិយមនៅដើមសតវត្សរ៍ទី២០ (រូបលេខ៩)។[3] ចំណែកគំនូរពិតានលើល្វែងគ្រឹះ ជាពិតានឈើដែលសល់មកតាំងពីដើម ហើយគំនូរបង្ហាញពីសាច់រឿងផ្សេងៗ និងគំនូរព្រះអាទិត្យព្រះចន្ទ។ គំនូរលើពិតាននេះ មានសាច់រឿងព្រះមាល័យទេសនានៅឋានតាវត្តឹង្ស ដែលពុំសូវមានអ្នកចាប់អារម្មណ៍ពីមុនមកទេ។ គំនូរនេះភាគច្រើនគេគូរព្រះចូឡាមណីចេតិយនៅចំកណ្ដាល មានទេវតាច្រើនអង្គប្រជុំគ្នាខាងមុខព្រះចូឡាមណីចេតិយ ដើម្បីថ្វាយបង្គំ បូជាទៀនធូប ផ្កាភ្ញី និងសណ្ដាប់ព្រះមាល័យទេសនា។ អ្វីដែលគួរឲ្យចាប់អារម្មណ៍ទៅទៀត គឺឥរិយាបថព្រះមាល័យកាន់តាលបណ្ណ(ផ្ចិតស្លឹកត្នោត)នៅព្រះហស្តម្ខាង និងព្រះហស្តម្ខាងទៀតចង្អុលឡើងលើ (រូបលេខ១០)។[4] រីឯគំនូរតូចៗនៅតាមហប់ខ្យល់ជុំវិញនោះវិញ គូររៀបរាប់រឿងពុទ្ធប្រវត្តិដែលចាប់ផ្ដើមពីចំហៀងខាងត្បូងត្រង់ចុងខាងកើត (រូបលេខ១១-១៣)។



រូបលេខ៩-១០ សិល្បៈលម្អលើធ្នឹម និងគំនូរលើពិតានឈើ

3 សូមអាន៖ ព្រាប ចាន់ម៉ារ៉ា, ២០០៩-២០១០: ៣៨-៤១

4 សូមអានបន្ថែម៖ "គំនូរព្រះមាល័យទេសនា" ដោយ រឹម ទិត្យបញ្ញា ផ្សាយលើគំណ https://khmercivilization.ams.com.kh/detail/28862 ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត







រូបលេខ១១-១៣ ផ្នែកខ្លះៗនៃគំនូរតូចៗលើហប់ខ្យល់

ជារួមមក ព្រះវិហារបុរាណវត្តទ្រាំង គឺជាសំណង់ដែលនៅសេសសល់ស្លាកស្នាមសិល្បៈចាស់ប្រមាណជាង១០០ឆ្នាំមុន។ គ្រឿងបង្គុំឈើ និងក្បាច់លម្អខ្លះបានជួសជុលជាបន្តបន្ទាប់ ហើយមួយផ្នែកនៅរក្សាបានទម្រង់សិល្បៈដើមគួរឲ្យកត់សម្គាល់។ លើសពីនេះ សាច់រឿងគំនូរខ្លះក្នុងព្រះវិហារវត្តទ្រាំង ជាសាច់រឿងកម្រឃើញលើកមកគូរនៅតាមព្រះវិហារផ្សេងៗ៕

អត្ថបទដោយ៖ ហឿន សុវណ្ណមរកត

# ឯកសារយោង

ព្រាប ចាន់ម៉ារ៉ា

២០០៩-២០១០, "គំនូរបុក", *កម្រងអត្ថបទក្នុងបណ្តាញព័ត៌មានវប្បធម៌ខ្មែរ, លេខ៩*, ទំ.៣៨-៤១, Friends of Khmer Culture, ភ្នំពេញ

២០១៧, *សំណង់នៅតាមវត្ត*, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ

ដានីញ៉ែល និង ដូមីនិក-ព្យែរ ហ្គេរេត៍

២០១៧, *វត្តអារាមនៅប្រទេសកម្ពុជា*, KAM edition, ភ្នំពេញ

រឹម ទិត្យបញ្ញា "គំនូរព្រះមាល័យទេសនា" ផ្សាយលើតំណ

https://khmercivilization.ams.com.kh/detail/28862 ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត